នស/រកម/០៥០៨/០១៦

# ព្រះរាជក្រម

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានអនុម័តកាលពីថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនេះ មានគោលដៅកំណត់គោលការណ៍ជាមូលដ្ឋានសម្រាប់គ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈទាំងមូល និង សម្រាប់រៀបចំច្បាប់ហិរញ្ញវត្ថុជាពិសេសសម្រាប់ជំហាននីមួយៗនៃដំណើរការរៀបចំ អនុម័ត និង អនុវត្តថវិកា ការត្រួតពិនិត្យលទ្ធផលថវិកា ការកំណត់មុខងារ ការទទួលខុសត្រូវ ព្រមទាំងកម្មវិបាកលើកំហុសឆ្គងក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល គ្រឹះស្ថានសាធារណៈ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ២.-**

ច្បាប់នេះ មានគោលបំណងគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយគោរពគោលការណ៍ បូរណភាព អាជ្ញាភាព ឯកត្តភាព សមាគតភាព សកលភាព សង្គតិភាព គណនេយ្យភាព តម្លាភាព ស្ថិរភាព ភាពគ្រប់ជ្រុងជ្រោយ និង សមិទ្ធកម្ម ។ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ គ្របដណ្តប់ទាំងហិរញ្ញវត្ថុសាធារណៈជាតិ ទាំងទំនាក់ទំនង និង អន្តរសកម្មរវាងហិរញ្ញវត្ថុសាធារណៈជាតិ ហិរញ្ញវត្ថុសាធារណៈអន្តរជាតិ ហិរញ្ញវត្ថុឯកជនជាតិ និង ហិរញ្ញវត្ថុឯកជនអន្តរជាតិ ហើយត្រូវធានាការគោរពគោលការណ៍ថវិកា គណនេយ្យភាពហិរញ្ញវត្ថុ ភាពផ្សារភ្ជាប់គ្នារវាងថវិកា និង គោលនយោបាយ និង គណនេយ្យភាពចំពោះសមិទ្ធកម្ម ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពជាច្បាប់គោល ដែលត្រូវយកធ្វើជាមូលដ្ឋាន និង ត្រូវគោរពអនុវត្តតាម សម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

សម្រាប់ប្រើប្រាស់នៅក្នុងច្បាប់នេះ វាក្យស័ព្ទខាងក្រោមមានន័យ ដូចតទៅ :

**ច្បាប់ហិរញ្ញវត្ថុ** សំដៅដល់ច្បាប់ដែលគ្រោងចំណូល និង ចំណាយប្រចាំឆ្នាំរបស់រដ្ឋ បទប្បញ្ញត្តិ ពាក់ព័ន្ធទៅនឹងវិស័យហិរញ្ញវត្ថុ និងការទូទាត់ផ្សេងៗ ដែលត្រូវបានប្រើប្រាស់សម្រាប់ការអនុវត្តមុខងារ កម្មវិធី និង ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ និង ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញ-វត្ថុសាធារណៈ និង បទប្បញ្ញត្តិស្តីពីវិស័យហិរញ្ញវត្ថុដែលច្បាប់កំណត់ ។

**ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ** គ្រោង និង អនុញ្ញាតសម្រាប់ឆ្នាំនីមួយៗនូវប្រភពធនធាន និងបន្ទុករបស់រដ្ឋ ។

**ច្បាប់កែតម្រូវ** សំដៅដល់ច្បាប់កែតម្រូវនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

**ច្បាប់ទូទាត់ថវិកា** សំដៅដល់ច្បាប់ត្រួតពិនិត្យ និង វាយតម្លៃលទ្ធផលនៃការអនុវត្តច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

**ក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែល** សំដៅដល់ក្រសួង ស្ថាប័ន ឬ អង្គភាព ដែលទទួលហិរញ្ញប្បទានទាំងស្រុង ឬ មួយផ្នែកនៃថវិកាជាតិ ឬ/ និង ដែលគ្រប់គ្រងទ្រព្យសកម្ម និង បំណុលរបស់រដ្ឋ ឬ/ និង គណនេយ្យ ដែលច្បាប់បង្កើត ព្រមទាំងគ្រប់គ្រងចាត់ចែងសកម្មភាពទាំងឡាយណាដែលនាំឱ្យរដ្ឋជាប់កាតព្វកិច្ចហិរញ្ញវត្ថុ ឬ បំណុលផ្សេងៗ ។

**រយៈពេលមធ្យម** សំដៅដល់រយៈពេលដែលមិនតិចជាង ៣ ឆ្នាំ និង មិនលើសពី ៥ ឆ្នាំ ។

**របៀបវារៈគោលនយោបាយ** សំដៅដល់យុទ្ធសាស្ត្រសម្រាប់សម្រេចចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ដែលឆ្លុះបញ្ចាំងនៅក្នុងផែនការរដ្ឋ ដែលរួមមានគោលនយោបាយជាតិ គោលនយោបាយតាមវិស័យ និង តាមអនុវិស័យ ។

**កម្មវិធី** សំដៅដល់ក្រុមនៃអនុកម្មវិធី ឬ/និង ក្រុមនៃចង្កោមសកម្មភាពដែលមានលក្ខណៈឯករាជ្យ តែមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ហើយត្រូវបានរៀបចំឡើងដើម្បីរួមចំណែកសម្រេចបាននូវគោលបំណង គោលនយោបាយរួមមួយ និងមានបញ្ជាក់ពីសកម្មភាព

ROYAUME DU CAMBODGE

ដែលត្រូវអនុវត្តលទ្ធផលក្នុងឆ្នាំ លទ្ធផលចុងក្រោយ ព្រមទាំងសូចនាករដែលជាមូលដ្ឋានសម្រាប់ការត្រួតពិនិត្យនិងវាយតម្លៃលទ្ធផលសម្រេចបានពីការអនុវត្តកម្មវិធី ។ កម្មវិធីអាចត្រូវបានបែងចែកជាអនុកម្មវិធី ។

**ភាពគ្រប់ជ្រុងជ្រោយនៃថវិកា** សំដៅដល់ថវិកាពេញលេញដែលឆ្លុះបញ្ចាំងគ្រប់ប្រភពចំណូល និង គ្រប់មុខសញ្ញាចំណាយ ។

**តម្លាភាព** សំដៅដល់រាល់ច្បាប់ បទប្បញ្ញត្តិ គោលការណ៍ នីតិវិធី និង ការអនុវត្តទាំងឡាយ ត្រូវផ្សព្វផ្សាយ ដោយទូលាយសម្រាប់ក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈ និង សាធារណជន ។

**គណនេយ្យភាព** សំដៅដល់ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និង បុគ្គល ចំពោះមុខងារ និងភារកិច្ចដែលបានទទួលអនុវត្តតាមរយៈប្រព័ន្ធរបាយការណ៍ ។

**សង្គតិភាព** សំដៅដល់គ្រប់ក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់របស់ព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តគោលការណ៍តែមួយដោយប្រទាក់ក្រឡាគ្នា ។

**សកលភាពនៃថវិកា** សំដៅដល់គ្រប់ប្រភេទចំណូលទាំងអស់អាចប្រើប្រាស់សម្រាប់រាល់មុខចំណាយដោយគ្មានលក្ខខណ្ឌ ។

**សមាគតភាពនៃថវិកា** សំដៅដល់គ្រប់ប្រភេទចំណូលទាំងអស់ និងគ្រប់មុខសញ្ញាចំណាយទាំងអស់ត្រូវបង់ និងទូទាត់តាមរយៈប្រព័ន្ធគណនីទោលរបស់រតនាគារជាតិ ។

**បូរណភាព** សំដៅដល់ហិរញ្ញវត្ថុសាធារណៈមានប្រព័ន្ធតែមួយ ដែលមានលក្ខណៈពេញលេញ គ្រប់ជ្រុងជ្រោយ គ្មានការប្រទាំងប្រទើសទាំងផ្នែកគោលនយោបាយ ទាំងក្របខ័ណ្ឌច្បាប់ និង ស្ថាប័ន ហើយដែលមិនអាចរំលោភបំពានបាន ។

**រដ្ឋបាលថ្នាក់ជាតិ** សំដៅដល់ ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងមន្ទីរជំនាញក្រោមឱវាទ ។

**រដ្ឋបាលថ្នាក់ក្រោមជាតិ** សំដៅដល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ ។

**ថវិកា** សំដៅដល់សិណ្ឋុំនៃគណនីដែលពិពណ៌នាសម្រាប់ឆ្នាំនីមួយៗអំពីធនធានអចិន្ត្រៃយ៍ និងបន្ទុកអចិន្ត្រៃយ៍ទាំងអស់របស់រដ្ឋ ឬ របស់ស្ថាប័ន ឬ របស់អង្គភាពណាមួយ ។

**ថវិកាជាតិ ឬ ថវិការដ្ឋ** សំដៅដល់គម្រោងតុល្យភាពនៃធនធានអចិន្ត្រៃយ៍ និងបន្ទុកអចិន្ត្រៃយ៍ទាំងអស់របស់រដ្ឋ ។ ថវិកាជាតិ ឬ ថវិការដ្ឋ រួមមានថវិកាថ្នាក់ជាតិ និង ថវិកាថ្នាក់ក្រោមជាតិ ។ ថវិកាថ្នាក់ជាតិ គឺជាថវិការបស់រដ្ឋបាលថ្នាក់ជាតិ ។ ថវិកាថ្នាក់ក្រោមជាតិ គឺជាថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**អចលកម្មហិរញ្ញវត្ថុ** សំដៅដល់ការវិនិយោគលើមូលបត្រ ឬ មូលបត្រ ដែលបានមកពីការចូលរួមទុនជាមួយសហគ្រាស ឬ ក្រុមហ៊ុន ។ អចលកម្មហិរញ្ញវត្ថុនេះ ជាទ្រព្យសកម្មហិរញ្ញវត្ថុថេរមិនចរន្ត ។ ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលជាអចលកម្មហិរញ្ញវត្ថុ រួមមានមូលបត្រគ្រប់ប្រភេទទាំងអស់ វិញ្ញាបនបត្រផ្ញើប្រាក់ ប័ណ្ណសន្យារ៉ាប់រង ផលប័ត្រពាណិជ្ជកម្ម ប័ណ្ណសងតាមបញ្ជា រូបិយណត្តិ និង មូលប្បទានបត្រជាដើម ។

**ផលហិរញ្ញវត្ថុ** សំដៅដល់ផលហិរញ្ញវត្ថុទាំងអស់ដែលបានមកដោយការយកអតិរេកសាច់ប្រាក់បណ្តោះអាសន្ន ទៅវិនិយោគលើមូលបត្រអាចជួញដូរបាន និង ក្នុងរយៈពេលខ្លី ។ ផលហិរញ្ញវត្ថុនេះមានជាអាទិ៍ អត្រាការប្រាក់លើបំណុលប្រាក់ចំណេញ ដែលបានមកពីការវិនិយោគក្នុងរយៈពេលមួយយប់លើប័ណ្ណរតនាគារបរទេស ផលដែលបានមកពីការធានាឱ្យមានសំវិធានធន និង កម្រៃផ្សេងទៀត ដែលបានមកពីប្រតិបត្តិការហិរញ្ញវត្ថុ ។

**មាត្រា ៥.-**

ថវិកាត្រូវមានគោលការណ៍គន្លឹះ ១១ យ៉ាង ដែលត្រូវអនុវត្តជាចំខាតគឺ :

១- ភាពជាអាជ្ញា

២- ការិយបរិច្ឆេទមានកាលកំណត់មួយឆ្នាំ

៣- ភាពគ្រប់ជ្រុងជ្រោយ

៤- ឯកត្តភាព

៥- សកលភាព

៦- វិសេសភាព

៧- តុល្យភាព

៨- គណនេយ្យភាព

៩- តម្លាភាព

១០- ស្ថិរភាព

១១- សមិទ្ធកម្ម ។

**មាត្រា ៦.-**

រដ្ឋបាលថ្នាក់ជាតិ គ្រឹះស្ថានសាធារណៈ រដ្ឋបាលថ្នាក់ក្រោមជាតិ បុគ្គលដែលជាមន្ត្រីសាធារណៈ និង ប្រតិបត្តិករនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈទាំងមូល ត្រូវប្រកាន់ខ្ជាប់នូវមូលដ្ឋាននៃគោលការណ៍បូរណភាព សមាគតភាព សង្គតិភាព គណនេយ្យភាព តម្លាភាពនិងភាពគ្រប់ជ្រុងជ្រោយ ព្រមទាំងវិសាលភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល និងគោលការណ៍គន្លឹះទាំង ១១ យ៉ាងនៃថវិកា ។

**មាត្រា ៧.-**

ដើម្បីធានាការអនុវត្តច្បាប់នេះ និង បទប្បញ្ញត្តិនៃច្បាប់ពាក់ព័ន្ធផ្សេងទៀតប្រកប ដោយប្រសិទ្ធភាព ត្រូវចេញអនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា និង សារាចរណែនាំដោយរាជរដ្ឋាភិបាល ព្រមទាំងប្រកាស និង សារាចរណែនាំផ្សេងៗទៀត ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ៨.-**

ច្បាប់ដែលមានលក្ខណៈជាច្បាប់ហិរញ្ញវត្ថុរួមមាន :

១- ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ

២- ច្បាប់កែតម្រូវ

៣- ច្បាប់ទូទាត់ថវិកា ។

**មាត្រា ៩.-**

ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ គ្រោង និង អនុញ្ញាតសម្រាប់ឆ្នាំនីមួយៗនូវប្រភពធនធាននិងបន្ទុកដែលត្រូវចំណាយសរុបរបស់រដ្ឋ ដើម្បីបម្រើឱ្យរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គម ដោយគិតគូរដល់ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច សមតាហិរញ្ញវត្ថុ និង រូបិយវត្ថុជាសារវន្ត ពិសេសតាមរយៈការធានាឱ្យបាននូវតុល្យភាពថវិកា ។

**មាត្រា ១០.-**

ក្រៅពីអ្វីដែលមានចែងក្នុងច្បាប់នេះ របបហិរញ្ញវត្ថុ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាកម្មវត្ថុនៃច្បាប់ដោយឡែក ។

**មាត្រា ១១.-**

ការិយបរិច្ឆេទនៃឆ្នាំថវិកាចាប់ផ្តើមនៅថ្ងៃទី ០១ ខែ មករា ហើយបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ។

## ជំពូកទី ២
## រចនាសម្ព័ន្ធថវិកា និង សិទ្ធិអំណាច

### ផ្នែកទី ១
### រចនាសម្ព័ន្ធថវិកា

**មាត្រា ១២.-**

ថវិកាត្រូវរៀបចំ ទៅតាមចំណាត់ថ្នាក់រដ្ឋបាលដែលផ្អែកលើរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល ចំណាត់ថ្នាក់សេដ្ឋកិច្ចដែលផ្អែកទៅលើប្រភេទចំណាយ ចំណាត់ថ្នាក់មុខងារដែលផ្អែកទៅលើគោលបំណង និង ចំណាត់ថ្នាក់តាមកម្មវិធី ។

**មាត្រា ១៣.-**

ធនធានអចិន្ត្រៃយ៍របស់រដ្ឋមាន ចំណូលចរន្ត និង ចំណូលមូលធន ។

-ចំណូលចរន្ត ត្រូវបានបែងចែកជា ២ ក្រុម និង ៣ ប្រភេទគឺ :

• ក្រុមទី ១ : ចំណូលពិត

-ប្រភេទទី ១ : ចំណូលសារពើពន្ធ

-ប្រភេទទី ២ : ចំណូលមិនមែនសារពើពន្ធ

• ក្រុមទី ២ : ចំណូលតាមដីកា

-ប្រភេទទី ៣ : ចំណូលតាមដីកា

-ចំណូលមូលធន ត្រូវបានបែងចែកជា ២ ក្រុម និង ៣ ប្រភេទគឺ :

• ក្រុមទី ១ : ចំណូលពិត

-ប្រភេទទី ១ : ចំណូលពីប្រភពផ្ទាល់

-ប្រភេទទី ២ : ចំណូលពីប្រភពខាងក្រៅ

• ក្រុមទី ២ : ចំណូលតាមដីកា

-ប្រភេទទី ៣ : ចំណូលតាមដីកា

ប្រភេទចំណូលនីមួយៗ ត្រូវបានធ្វើចំណាត់ថ្នាក់ជាជំពូក គណនី អនុគណនី និង ជាយថាហេតុអាចលម្អិតជាងនេះទៀត ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៤.-**

គណនីថវិការួមមាន ថវិការដ្ឋ ថវិកាឧបសម្ព័ន្ធ ថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល និង គណនីពិសេសរតនាគារជាតិ ។ គណនីថវិកាផ្សេងៗទៀត អាចបង្កើតបានក្នុងច្បាប់ហិរញ្ញវត្ថុ ។

ថវិកាឧបសម្ព័ន្ធអនុវត្តចំពោះអង្គភាពរដ្ឋ ដែលមានលក្ខណៈឧស្សាហកម្ម និងពាណិជ្ជកម្ម ដែលមិនមែនជានីតិបុគ្គល ។ ថវិកាឧបសម្ព័ន្ធ ត្រូវបង្កើត ឬ លុបចោល ដោយច្បាប់ហិរញ្ញវត្ថុ ។ កិច្ចប្រតិបត្តិការនៃថវិកាឧបសម្ព័ន្ធ ត្រូវប្រព្រឹត្តទៅក្នុងលក្ខខណ្ឌ និង តាមវិធានដូចគ្នានឹងកិច្ចប្រតិបត្តិការថវិការដ្ឋដែរ ។

គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវមានថវិកាស្វយ័ត ។ ប្រភពធនធានជាប្រចាំរបស់គ្រឹះ-ស្ថានសាធារណៈរដ្ឋបាលរួមមាន ចំណូលផ្ទាល់ និង ជាយថាហេតុ មានការឧបត្ថម្ភ តុល្យភាពដោយថវិការដ្ឋ ។ រីឯចំណាយជាប្រចាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវគោរពតាមវិធាននៃចំណាត់ថ្នាក់ និង ការគ្រប់គ្រងដូចចំណាយជាប្រចាំរបស់ថវិការដ្ឋដែរ ។

ការរៀបចំ និង ការប្រព្រឹត្តទៅនៃថវិកាឧបសម្ព័ន្ធ និង ថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវកំណត់ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល ។

**មាត្រា ១៥.-**

ចំណូលសារពើពន្ធរួមមានចំណូលបានមកពីពន្ធ និង អាករក្នុងប្រទេស និង ពន្ធ និង អាករលើពាណិជ្ជកម្មក្រៅប្រទេស និង ចំណូលសារពើពន្ធដទៃទៀត ។

ចំណូលមិនមែនសារពើពន្ធរួមមានចំណូលបានមកពីការជាក់ថែង ការធ្វើអាជីវកម្មនិង ការលក់ទ្រព្យសម្បត្តិរដ្ឋ ផលបានមកពីសម្បទាន កម្រៃបានមកពីសេវាសាធារណៈ ផលពីការពិន័យ និង ការដាក់ទណ្ឌកម្ម ការឧបត្ថម្ភអំណោយ ផលហិរញ្ញវត្ថុ ផលផ្សេងៗ និងផលពិសេស និង ចំណូលមិនមែនសារពើពន្ធដទៃទៀត ។

ចំណូលមូលធនរួមមានចំណូលបានមកពីអចលកម្មហិរញ្ញវត្ថុ ហិរញ្ញប្បទានឥតសំណងសម្រាប់វិនិយោគ ការខ្ចី និង ចំណូលមូលធនផ្សេងទៀត ។

**មាត្រា ១៦.-**

ពន្ធ អាករ និង ចំណូលសារពើពន្ធផ្សេងៗ ត្រូវកំណត់ដោយច្បាប់ និង ត្រូវប្រមូល និង ត្រួតពិនិត្យដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ អត្រាពន្ធ អាករ មូលដ្ឋានជាប់ពន្ធ ការលើកលែងពន្ធ និងវិវាទ ដែលទាក់ទងនឹងការកំណត់ការប្រមូល និង ការត្រួតពិនិត្យពន្ធ ត្រូវកំណត់នៅក្នុងក្របខ័ណ្ឌ និង តាមបែបបទ ដែលមានចែងនៅក្នុងច្បាប់ដែលទាក់ទងដល់ប្រភេទពន្ធ និង អាករនីមួយៗ ។

គ្មានបទប្បញ្ញត្តិណាមួយ ទោះជាប្រភេទណាក៏ដោយ គ្មានអនុសញ្ញាអន្តរជាតិណាមួយ ដែលអាចធ្វើឱ្យមានការប្រែប្រួលនាំមកនូវការ ចាត់ចំណូលនោះឡើយ ។ ករណីខាងលើអាច

ប្រព្រឹត្តទៅបានលុះត្រាតែអនុវត្តតាមទម្រង់ច្បាប់ និង បទបញ្ញាដូចគ្នា ក្រោយពីមានយោបល់ឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ការប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ១៧.-**

ទ្រព្យសម្បត្តិរដ្ឋ ដែលរួមមាន ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និង ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ត្រូវចាត់ចែង និង គ្រប់គ្រងយ៉ាងត្រឹមត្រូវទៅតាមបទប្បញ្ញត្តិនៃច្បាប់ និង បទបញ្ញាជាធរមាន ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋលើការលក់ ការជួល ការផ្ទេរ និង ការចាត់ចែងដទៃទៀតលើទ្រព្យសម្បត្តិរដ្ឋ ការផ្តល់សម្បទានផ្សេងៗរបស់រដ្ឋ ព្រមទាំងការធ្វើបញ្ជីសារពើភណ្ឌ ។ រាល់ការចុះកិច្ចសន្យាលើការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និង ផ្តល់សម្បទានផ្សេងៗរបស់រដ្ឋ ដែលមានការពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈ ត្រូវស្ថិតក្រោមការត្រួតពិនិត្យ និង ការឯកភាពរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ក្រោមបទប្បញ្ញត្តិនៃមាត្រា ១៩ នៃច្បាប់នេះ ចំណូលទាំងអស់ដែលបានពីការចាត់ចែង និង គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ត្រូវបង់ចូលគណនីទោលរបស់រតនាគារជាតិនៃថវិការដ្ឋ ដោយមិនអាចដកចំណូលនេះ ទៅកាត់កងដោយត្រង់ជាមួយចំណាយឡើយ ។

**មាត្រា ១៨.-**

សេវាបង់ថ្លៃរបស់រដ្ឋ គឺជាសេវា ដែលផ្តល់ដោយអង្គភាពសេវាសាធារណៈរបស់រដ្ឋទៅឱ្យឯកជន និង អង្គការតតិយ ។ កម្រៃសេវារបស់រដ្ឋ ត្រូវស្ថិតនៅក្រោមអានុភាពនៃតារាងតម្លៃ ដែលកំណត់ដោយរាជរដ្ឋាភិបាល តាមសំណើរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងតាមយោបល់របស់ក្រសួង និង ស្ថាប័នដែលពាក់ព័ន្ធ ។

ចំពោះកម្រៃសេវាសាធារណៈរបស់រដ្ឋ ដែលមានលក្ខណៈតូចតាច មានជាអាទិ៍កម្រៃពីការអនុញ្ញាតរដ្ឋបាល ទម្រង់ការរដ្ឋបាល ប័ណ្ណចូលទស្សនារមណីយដ្ឋាន សារមន្ទីរ វិក្កយបត្រ

ពិន័យ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័នដែលមានការ ពាក់ព័ន្ធ ។

**មាត្រា ១៩.-**

ចំណូលត្រូវកត់ត្រាចូលទាំងស្រុងហើយមិនត្រូវយកទៅកាត់កងដោយត្រង់ជាមួយចំណាយឡើយ ។ ការបង្កើនដោយអាណាប័កនូវទឹកប្រាក់នៃឥណទានដែលបានអនុម័ត ដោយសំអាងលើប្រាក់ចំណូលពិសេសណាមួយ ត្រូវបានហាមឃាត់ដាច់ខាត ។

**មាត្រា ២០.-**

ចំណូលទាំងមូល ត្រូវវិភាជន៍សម្រាប់រាល់មុខសញ្ញាចំណាយទាំងអស់ ។ ប៉ុន្តែចំណូលខ្លះ អាចត្រូវវិភាជន៍ សម្រាប់តែមុខសញ្ញាចំណាយជាក់ស្តែងណាមួយក្នុងទម្រង់ និង ក្រោមលក្ខខណ្ឌដែលត្រូវកំណត់ដោយច្បាប់ ។

**មាត្រា ២១.-**

បន្ទុកអចិន្ត្រៃយ៍របស់រដ្ឋរួមមាន ចំណាយចរន្ត និង ចំណាយមូលធន ។ បន្ទុកនេះ ត្រូវបានចែកជាក្រុម និង ប្រភេទ ។

**មាត្រា ២២.-**

ចំណាយចរន្តនៃថវិកាត្រូវបានបែងចែកជា ២ ក្រុម និង ៦ ប្រភេទគឺ :

- ក្រុមទី ១ : ចំណាយពិត
  - ប្រភេទទី ១ : មធ្យោបាយសេវា
  - ប្រភេទទី ២ : បន្ទុកហិរញ្ញវត្ថុ
  - ប្រភេទទី ៣ : អន្តរាគមន៍សាធារណៈ
  - ប្រភេទទី ៤ : ចំណាយផ្សេងៗ
- ក្រុមទី ២ : ចំណាយតាមដីកា និង ចំណាយមិនបានគ្រោងទុក
  - ប្រភេទទី ៥ : ចំណាយតាមដីកា

-ប្រភេទទី ៦ : ចំណាយមិនបានគ្រោងទុក

ប្រភេទចំណាយនីមួយៗ ត្រូវបានធ្វើចំណាត់ថ្នាក់ជាជំពូក គណនី អនុគណនី និងជាយថាហេតុ អាចលម្អិតជាងនេះទៀត ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ២៣.-**

ចំណាយមូលធននៃថវិកា គឺសម្រាប់ការអនុវត្តកម្មវិធី ការអនុវត្តគម្រោងវិនិយោគ ការចូលរួមភាគកម្ម និង ការទូទាត់បំណុល ។

ចំណាយមូលធនត្រូវបានបែងចែកជា ២ ក្រុម និង ៣ ប្រភេទគឺ :

- ក្រុមទី ១ : ចំណាយពិត
  - -ប្រភេទទី ១ : ការទូទាត់ប្រាក់ខ្ចី និង បំណុលប្រហាក់ប្រហែល
  - -ប្រភេទទី ២ : អចលកម្ម
- ក្រុមទី ២ : ចំណាយតាមដីកា
  - -ប្រភេទទី ៣ : ចំណាយតាមដីកា

ប្រភេទចំណាយនីមួយៗ ត្រូវធ្វើចំណាត់ថ្នាក់ជាជំពូក គណនី អនុគណនី និង ជាយថាហេតុអាចលម្អិតជាងនេះទៀត ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ឥណទានវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស គឺជាឥណទានមានលក្ខណៈជាប់ស្លាន ហើយពុំអាចធ្វើជាកម្មវត្ថុនៃនិយ័តភាពទៅប្រភេទចំណាយណាមួយផ្សេងទៀតបានឡើយ ។

**មាត្រា ២៤.-**

ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ វិភាជន៍ឥណទានទៅតាមក្រសួង ស្ថាប័ន និង អង្គភាពសាធារណៈប្រហាក់ប្រហែល ដោយឆ្លុះបញ្ចាំងឱ្យឃើញផងដែរនូវថវិកាឧបសម្ព័ន្ធ និង ថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលទៅតាមប្រភេទចំណាយចរន្ត និង ចំណាយមូលធន ។ ក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែលទាំងនោះ ប្រមូលផ្តុំឥណទានទាំងអស់សម្រាប់បម្រើការងាររបស់ខ្លួននៅរដ្ឋបាលថ្នាក់ជាតិ ។

ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវវិភាជន៍ឥណទានជាកញ្ចប់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
REGISTRE du PALAIS ROYAL

មាត្រា ២៥.-

ឥណទានថវិកា ដែលបានអនុម័តដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវបានបែងចែកលម្អិតនៅក្នុងផ្នែកក្នុងប្រភេទនីមួយៗទៅតាមលក្ខណៈ និង គោលដៅនៃឥណទានថវិកា ។ ឥណទានទាំងនេះ អាចធ្វើជាកម្មវត្ថុសម្រាប់ការរៀបចំថវិកាតាមកម្មវិធី និង ការប្រមូលផ្តុំតាមវិស័យផងដែរ ។ ការរៀបចំថវិកាតាមកម្មវិធី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ចំណាយចរន្តនៃប្រភេទ២ "បន្ទុកហិរញ្ញវត្ថុ" និង ប្រភេទ៦ "ចំណាយមិនបានគ្រោងទុក" មិនត្រូវបានបែងចែកឱ្យទៅក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែលណាមួយឡើយ ។ ឥណទាននេះ ទុកសម្រាប់សងការប្រាក់នៃប្រាក់ខ្ចី និង បន្ទុកហិរញ្ញវត្ថុផ្សេងៗ ព្រមទាំងឥណទានត្រៀមបម្រុងសម្រាប់ចំណាយផ្សេងៗលើមុខសញ្ញាដែលកើតឡើងជាយថាហេតុ ។ ឥណទានត្រៀមបម្រុង ត្រូវបានអនុញ្ញាតសម្រាប់ការចំណាយទាំងឡាយណាដែលការបែងចែកមិនអាចត្រូវបានកំណត់ជាក់លាក់ នៅពេលដែលឥណទាននោះ ត្រូវបានអនុម័ត ។ ការបែងចែកឥណទានត្រៀមបម្រុងទាំងនេះ តាមក្រសួង ស្ថាប័ន និង អង្គភាពសាធារណៈប្រហាក់ប្រហែលនីមួយៗ ត្រូវធ្វើឡើងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ប្រភេទ ១ នៃចំណាយមូលធន គឺសម្រាប់ការទូទាត់ប្រាក់ខ្ចីនៅក្នុងប្រទេស និង ពីក្រៅប្រទេស និង ទូទាត់បំណុលប្រហាក់ប្រហែល ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គឺជាអាណាប័កចំណាយលើការប្រាក់នៃការខ្ចី ចំណាយផ្សេងៗ ចំណាយសំណង និង ចំណាយបង្វិលសងវិញ ព្រមទាំងចំណាយទូទាត់ប្រាក់ខ្ចីនៅក្នុងប្រទេស និង ពីក្រៅប្រទេស និង ទូទាត់បំណុលប្រហាក់ប្រហែល ។

មាត្រា ២៦.-

ឥណទានថវិកាមានពីរប្រភេទគឺ កំហិតកំណត់ និង ប៉ាន់ប្រមាណ ។ ឥណទានកំហិតកំណត់គឺត្រូវបានផ្តល់ជាការសន្យា និង ការអនុញ្ញាតត្រឹមកម្រិតខ្ពស់បំផុតមួយ ដែលចំណាយ

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ប្រភេទនេះ ត្រូវបានកំណត់ជាមុន ។ ចំណាយបែបនេះ អាចបង្កើនបានតែតាមរយៈច្បាប់កែតម្រូវនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំតែមួយប៉ុណ្ណោះ ។ ឥណទានចាំន់ប្រមាណ គឺត្រូវបានអនុញ្ញាតសម្រាប់ចំណាយចាំបាច់ និង ក្នុងករណីដែលការគ្រោងមិនគ្រប់គ្រាន់នៅក្នុងដំណាក់កាលបន្ទាប់ពីការអនុម័តថវិកា ។ ចំណាយនៃឥណទានប្រភេទនេះ អាចនឹងត្រូវបានប្រើប្រាស់លើសពីឥណទាន ដែលបានគ្រោងនៅក្នុងជំពូកថវិកាពាក់ព័ន្ធ ។ ឥណទានប្រភេទនេះ កើតមានលើបំណុលសាធារណៈ បៀវត្សរ៍ ប្រាក់បំណាច់របស់បុគ្គលិកវិភាគទានសមាជិកភាព ចំពោះស្ថាប័នអន្តរជាតិ ឬ អន្តររដ្ឋាភិបាល និង ចំណាយផ្សេងទៀត ដែលត្រូវកំណត់នៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

**មាត្រា ២៧.-**

ឥណទានចំណាយចរន្ត ត្រូវបែងចែកជាឥណទានសម្រាប់សកម្មភាពការងារ ដែលបានអនុម័ត និង ឥណទានសម្រាប់វិធានការថ្មី ។

ឥណទានសម្រាប់សកម្មភាពការងារដែលបានអនុម័ត រួមមានឥណទានដែលបានកំណត់នៅក្នុងថវិកាចំណាយចរន្តនៃឆ្នាំមុន ដកទាយជ្ជទាន និង ឥណទានសម្រាប់សកម្មភាពការងារ ដែលនឹងមិនកើតឡើងវិញនៅក្នុងឆ្នាំគ្រោងថវិកា បូកបន្ថែមឥណទាន សម្រាប់ការកែតម្រូវតាមស្ថានភាពជាក់ស្តែង ។

ឥណទានសម្រាប់សកម្មភាពការងារដែលបានអនុម័ត ត្រូវស្ថិតក្នុងកម្រិតអប្បបរមាចាំបាច់ ដែលត្រូវការសម្រាប់ដំណើរការសកម្មភាពការងារនៅក្នុងលក្ខខណ្ឌនៃឆ្នាំមុន ។

ការកែតម្រូវតាមស្ថានភាពជាក់ស្តែង ត្រូវគិតអំពីផលប៉ះពាល់ដែលបានកើតឡើងនៅក្នុងឆ្នាំមុន ព្រមទាំងការវិវត្តនៃបន្ទុកសាធារណៈខ្លះទៀត ដែលអាចកើតឡើងដោយសារវិធានការដែលបានអនុម័តនៅក្នុងឆ្នាំមុន ។

វិធានការថ្មី គឺទាក់ទងទៅនឹងការសម្រេចទាំងឡាយណាដែលនាំឱ្យមានផលប៉ះពាល់ហិរញ្ញវត្ថុបន្ថែមទៀតទៅលើថវិកា ។

ROYAUME DU CAMBODGE PALAIS ROYAL

**មាត្រា ២៨.-**

ឥណទានចំណាយមូលធន គឺជាឥណទានវិនិយោគដែលត្រូវបែងចែកជាឥណទានភ្ជាប់សន្យា និង ឥណទានទូទាត់ ។ ឥណទានវិនិយោគ កំណត់លើកម្មវិធី ឬ គម្រោងការទាំងឡាយដែលរដ្ឋបានផ្តួចផ្តើមនៅក្នុងឆ្នាំ និងគណនាតម្រូវការចំណាយសរុប ។ ឥណទានវិនិយោគគ្រោងមូលនិធិភ្ជាប់សន្យាសម្រាប់ប្រតិបត្តិការទាំងស្រុងនៃគម្រោងការ ដោយមិនតម្រូវឱ្យមានការវិនិយោគបន្ថែមសម្រាប់បញ្ចប់នោះទេ ។ ទោះជាយ៉ាងនោះក្តី ឥណទានវិនិយោគអនុញ្ញាតឱ្យរាជរដ្ឋាភិបាលធ្វើការសន្យាត្រឹមតែក្នុងរង្វង់នៃឥណទានភ្ជាប់សន្យា ដែលបានអនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំតែប៉ុណ្ណោះ ។

ឥណទានភ្ជាប់សន្យា ត្រូវដាក់នៅក្រោមអាណាប័ក សម្រាប់ចំណាយចាំបាច់ក្នុងការអនុវត្តកិច្ចវិនិយោគ ដែលបានកំណត់នៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។ ឥណទានទូទាត់ ត្រូវប្រើប្រាស់សម្រាប់ចេញបញ្ជាចំណាយដែលជាបន្ទុករបស់រដ្ឋ នៅក្នុងកម្រិតនៃឥណទានភ្ជាប់សន្យា ។

**មាត្រា ២៩.-**

ឥណទានភ្ជាប់សន្យាអាចមានតម្លៃគ្មានកំណត់ពេល ។ ឥណទាននេះ ត្រូវបានយោងពីមួយឆ្នាំទៅមួយឆ្នាំ រហូតដល់ការលុបបំបាត់ជាយថាហេតុ ។ ឥណទានទូទាត់ ដែលមិនបានប្រើនៅពេលបិទការគ្រប់គ្រង (បញ្ចប់ឆ្នាំ) ត្រូវបានលុបចោល និង អាចអនុញ្ញាតឥណទានថ្មីសម្រាប់ឆ្នាំបន្ទាប់ ។

**មាត្រា ៣០.-**

គ្មានវិធានការជាបទប្បញ្ញត្តិ បទបញ្ជា ឬ រដ្ឋបាលណាមួយអាចត្រូវបានអនុម័តទទួលស្គាល់ ឬ សម្រេចបានទេ ប្រសិនបើតម្រូវការចំណាយនៃបន្ទុកថ្មីដែលនឹងកើតឡើងនោះ មិនត្រូវបានវាយតម្លៃ ព្យាករណ៍ និង អនុញ្ញាតមុនពេលគ្រោង និង កំណត់ថវិកា ។ ការបង្កើតនិរការប្តូរមុខរបរក៏ដូចជាការប្រឡងជ្រើសរើស អាចកើតមានតែពីតារាងមុខរបរដែលបានកំណត់ដោយរដ្ឋបាល ឬ អង្គភាព និង បានគ្រោងនៅក្នុងថវិកា ។ ការដំឡើងឋានៈ ការផ្តល់បុព្វលាភ

ថ្មី ឬ ការបង្កើន លាភការ មិនអាចសម្រេចបានទេ បើប្រសិនណាវិធានការទាំងនេះមិនបាន បំពេញ ដោយឥណទានគ្រប់គ្រាន់ជាមុននៅក្នុងថវិការដ្ឋ ។

**មាត្រា ៣១.-**

គណនីពិសេសរបស់រតនាគារជាតិ គឺជាគណនីដែលបានបើកក្នុងលេខនារបស់រតនាគារជាតិទុកសម្រាប់ៈ

១-ចុះកិច្ចបញ្ជីការ ចំណូលដោយឡែកជាហិរញ្ញប្បទានជាក់លាក់ដល់កិច្ចប្រតិបត្តិការសេវាសាធារណៈទាំងឡាយ ដែលហៅថាគណនីចាត់ចែងពិសេស ។

២-បង្ហាញចំណាយមានលក្ខណៈបណ្តោះអាសន្នរបស់រដ្ឋ ដែលហៅថាគណនីបុរេប្រទាន ។

៣-កត់ត្រាប្រតិបត្តិការទាំងអស់មានលក្ខណៈឧស្សាហកម្ម ឬ ពាណិជ្ជកម្មដែលបានធ្វើដោយរដ្ឋជាលក្ខណៈបន្ទាប់បន្សំ ដែលហៅថាគណនីពាណិជ្ជកម្ម ។

គណនីពិសេសរបស់រតនាគារជាតិ ត្រូវបានបង្កើត ឬ លុបចោលដោយច្បាប់ហិរញ្ញវត្ថុ ក្រោមលក្ខខណ្ឌនៃបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៣២.-**

ចំណូល និង ចំណាយទាំងអស់នៃគណនីពិសេសរបស់រតនាគារជាតិ ត្រូវបានគ្រោង និង អនុញ្ញាតក្នុងលក្ខខណ្ឌដូចគ្នាទៅនឹងប្រតិបត្តិការទូទៅនៃថវិការដ្ឋដែរ ។

**មាត្រា ៣៣.-**

ប្រតិបត្តិការចំណាយ ដែលអាចកត់ត្រាក្នុងគណនីពិសេសរបស់រតនាគារជាតិ ត្រូវប្រព្រឹត្តទៅដូចជាថវិការដ្ឋដែរ ក្រោមលក្ខខណ្ឌនៃចំណុចដោយឡែកដូចតទៅៈ

១-ចំណាយសរុបដែលបានសន្យា ឬ បានចេញអាណត្តិទៅឱ្យគណនីពិសេសរបស់រតនាគារជាតិ មិនអាចលើសពីធនធានសរុបរបស់គណនីនេះទេ

២-ក្នុងពេលគ្រប់គ្រង ប្រសិនបើចំណូលនៃគណនីពិសេសរបស់រតនាគារជាតិ

បានស្តែងឡើងខ្ពស់ជាងចំណាយប៉ាន់ប្រមាណដែលបានគ្រោងទុក នោះឥណទាននៃគណនីនេះ អាចត្រូវបានតម្លើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុក្នុងកម្រិតនៃចំណូលដែលលើសនោះ ។

៣-សមតុល្យឥណទានៃគណនីពិសេសរបស់រតនាគារជាតិ អាចយោងពីមួយឆ្នាំទៅមួយឆ្នាំ លើកលែងតែមានបទប្បញ្ញត្តិផ្ទុយដែលមានចែងក្នុងច្បាប់ហិរញ្ញវត្ថុ ។

៤-ហាមកត់ត្រាក្នុងគណនីពិសេសរបស់រតនាគារជាតិនូវចំណាយណាដែលមិនចូលក្នុងក្របខ័ណ្ឌនៃកម្មវត្ថុរបស់គណនីនេះ មានជាអាទិ៍ ប្រាក់បៀវត្សរ៍ ឬ ប្រាក់បំណាច់ ។

## ផ្នែកទី ២
## សិទ្ធិអំណាច និង ការទទួលខុសត្រូវ

**មាត្រា ៣៤.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងចំណូល ចំណាយ ការខ្ចី ការឱ្យខ្ចី និង ការធានារបស់រដ្ឋ ដែលត្រូវបានអនុញ្ញាតដោយច្បាប់ ។

**មាត្រា ៣៥.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំ ការអនុវត្ត ការតាមដាន និង ការគ្រប់គ្រងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និង រយៈពេលវែងរបស់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣៦.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវរាយការណ៍ជូនរដ្ឋសភា និង ព្រឹទ្ធសភាអំពីគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋា-

ROYAUME DU CAMBODGE ROYAL ... ព្រះរាជក្រឹត្យ

ភិបាល ព្រមទាំងអំពីស្ថានភាពសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈនាពេលបច្ចុប្បន្ន និង ព្យាករណ៍សម្រាប់រយៈពេលមធ្យម ។

**មាត្រា ៣៧.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារកិច្ចដឹកនាំការរក្សាវិន័យហិរញ្ញវត្ថុសាធារណៈ ការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ ការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ការគោរពច្បាប់ហិរញ្ញវត្ថុ ព្រមទាំងធានាការត្រួតពិនិត្យជាប្រចាំលើការគ្រប់គ្រងថវិកា ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារកិច្ចផ្តល់របាយការណ៍អំពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និង ស្ថានភាពហិរញ្ញវត្ថុសាធារណៈជូនរដ្ឋសភា និង ព្រឹទ្ធសភាពីរដងក្នុង ១ ឆ្នាំ គឺនៅពេលពិភាក្សាអនុម័តសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និង នៅពាក់កណ្តាលឆ្នាំ ។

**មាត្រា ៣៨.-**

រដ្ឋបាលថ្នាក់ជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិ មានភារកិច្ចទទួលខុសត្រូវក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ការគ្រប់គ្រងថវិកា និង ការត្រួតពិនិត្យការអនុវត្តថវិការបស់ខ្លួន ជាពិសេសត្រូវមានគណនេយ្យភាពចំពោះការកំណត់ និង លទ្ធផលនៃការអនុវត្តគោលនយោបាយនៅក្នុងវិស័យរបស់ខ្លួន ដែលស្របទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

## ជំពូកទី ៣
## ការរៀបចំថវិកា
### ផ្នែកទី ១
### ក្របខ័ណ្ឌនៃការរៀបចំថវិកា

**មាត្រា ៣៩.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំតាមប្រតិទិនដូចខាងក្រោមនេះ :

**១-ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (ពីខែ មីនា ដល់ ខែ ឧសភា)**

នៅសប្តាហ៍ទីមួយនៃខែមីនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរៀបចំក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ដែលមានសង្គតិភាពទៅនឹងក្របខ័ណ្ឌគោលនយោបាយជាតិសម្រាប់ការអភិវឌ្ឍ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និង សម្រេច ។

នៅសប្តាហ៍ទីមួយនៃខែមេសា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវចេញសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដោយផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមដែលបានកំណត់ដោយរាជរដ្ឋាភិបាល ។

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល និង អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្អែកលើសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ចក្ខុវិស័យ គោលបំណង គោលដៅនៃកម្មវិធី និង ផែនការសកម្មភាពជាអាទិភាពរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបម្រើឱ្យគោលនយោបាយអាទិភាពរបស់វិស័យ និង គោលនយោបាយជាតិសម្រាប់ការអភិវឌ្ឍ ។ ផែនការយុទ្ធសាស្ត្រថវិកា ទាំងនេះត្រូវផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ ខែ ឧសភា ។

**២-ការរៀបចំកញ្ចប់ថវិកា (ពីខែ មិថុនា ដល់ ខែកញ្ញា)**

នៅសប្តាហ៍ទីមួយនៃខែមិថុនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរៀបចំសេចក្តីព្រាងសារាចរណែនាំស្តីពីបច្ចេកទេសនៃការរៀបចំគម្រោងថវិកា ដោយបញ្ជាក់ជូននូវទម្រង់បែបបទ និងនីតិវិធីនៃការរៀបចំគម្រោងថវិកា ព្រមទាំងផ្ញើគំរូបង្ហាញនិងឯកសារពាក់ព័ន្ធ ដែលត្រូវភ្ជាប់មកជាមួយ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និង សម្រេច ហើយផ្ញើជូនក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរៀបចំគម្រោងចំណូល ចំណាយថវិកាលម្អិតរបស់ខ្លួន ។

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល និង អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំនូវគម្រោងចំណូល ចំណាយថវិកាលម្អិតរបស់ខ្លួន សម្រាប់រដ្ឋបាលថ្នាក់ជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្អែកលើមូលដ្ឋានសារាចរណែនាំស្តីពីបច្ចេកទេសនៃការរៀបចំគម្រោងថវិកា និង អាទិភាពនៃគោលនយោបាយរបស់ខ្លួន ។ គម្រោងថវិកាទាំងនេះ ត្រូវផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ ខែ កក្កដា ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ធ្វើការប្រមូលផ្តុំបូកសរុបនូវគម្រោងចំណូលចំណាយថវិការបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល ខេត្ត និង រាជធានី ដែលបានស្នើឡើង ។

នៅក្នុងអំឡុងខែសីហាទាំងមូល ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុអញ្ជើញរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន និង ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែលព្រមទាំងអភិបាលគ្រប់ខេត្ត និង រាជធានី មកពិភាក្សាការពារគម្រោងថវិការបស់ខ្លួន ដើម្បីសម្របសម្រួលនូវគម្រោងចំណូល ចំណាយថវិកាទាំងនោះឱ្យបានសមស្របតាមបទប្បញ្ញត្តិនៃការណែនាំដោយមានការកាត់បន្ថយចំណាយណាដែលមិនចាំបាច់ និងបង្កើនចំណូលឱ្យបានសមស្រប ។

នៅក្នុងអំឡុងខែកញ្ញាទាំងមូល ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុធ្វើការបូកសរុបចំណូល ចំណាយរដ្ឋទាំងមូល ដើម្បីតុល្យភាពថវិកាឡើងវិញរួចរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ និង ធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ ។

**៣ -ការអនុម័តថវិកា (ពីខែ តុលា ដល់ ខែ ធ្នូ)**

នៅសប្តាហ៍ទីមួយនៃខែតុលា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បញ្ជូនសេចក្តីព្រាងច្បាប់នេះ ដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសំរេចរួចដាក់ជូនរដ្ឋសភានៅសប្តាហ៍ទីមួយនៃខែវិច្ឆិកា ដើម្បីពិនិត្យអនុម័ត និង ដាក់ជូនព្រឹទ្ធសភា នៅសប្តាហ៍ទីមួយនៃខែធ្នូ ដើម្បីឱ្យសេចក្តីព្រាងច្បាប់នេះ ត្រូវបានអនុម័តជាស្ថាពរមុនថ្ងៃទី ២៥ ខែ ធ្នូ ។

## ផ្នែកទី ២
## ដំណើរការនៃការរៀបចំថវិកា

**មាត្រា ៤០.-**

ការរៀបចំថវិកា ត្រូវគោរពបទប្បញ្ញត្តិដែលមានចែងនៅក្នុងមាត្រា ១ មាត្រា ២ និង មាត្រា ៦ នៃច្បាប់នេះ ។

**មាត្រា ៤១.-**

ការគ្រោងចំណូលចរន្ត ត្រូវឈរលើមូលដ្ឋាននៃប្រភពធនធានដែលបានមកពីចំណូលសារពើពន្ធ និង ចំណូលមិនមែនសារពើពន្ធ ។

១-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវគ្រោងដោយផ្ទាល់នូវចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ ដែលជាកម្មវត្ថុនៃការប្រមូលនៅក្រោមសមត្ថកិច្ចរបស់ខ្លួន និង គ្រោងចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធបានមកពីសហគ្រាសសាធារណៈ ។

២-រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល និង អភិបាលគ្រប់ខេត្ត និង រាជធានី ដែលមានចំណែកក្នុងការគ្រប់គ្រងចំណូលក្រោមសមត្ថកិច្ចរបស់ខ្លួន ត្រូវផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនូវបញ្ជីរាយគ្រប់មុខចំណូល និង បញ្ជីប៉ាន់ស្មានចំណូលទាំងអស់ ដើម្បីកត់ត្រាក្នុងគម្រោងចំណូលនៃថវិកាឱ្យបានពេញលេញ និង ត្រឹមត្រូវ ។ ចំណូលទាំងនេះជាចំណែក មិនអាចបំបែកបាននៃចំណូលសរុបនៃថវិការដ្ឋ ។

**មាត្រា ៤២.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវគ្រោងចំណូលមូលធនៈដោយឈរលើមូលដ្ឋាននៃប្រភពធនធានបានមកពី :

១-ចំណូលបានមកពីអចលកម្មហិរញ្ញវត្ថុ

២-ការសងបំណុល និង សងបុរេប្រទានដោយសហគ្រាសសាធារណៈ ដែលត្រូវ

ROYAUME DU CAMBODGE

កត់ត្រាឱ្យបានត្រឹមត្រូវក្នុងតារាងវិលល់

៣-រាល់ប្រភពចំណូលពីការខ្ចីក្នុងប្រទេស ដោយមានការសម្រេចយល់ព្រមពីរាជរដ្ឋាភិបាល ដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវវាយតម្លៃ និងវិភាគលើស្ថានការណ៍សេដ្ឋកិច្ច និង ចរិតនៃការខ្ចី ដោយសហការជាមួយទេសាភិបាលធនាគារជាតិនៃកម្ពុជា ។

៤-ហិរញ្ញប្បទានក្រៅប្រទេស ក្រោមរូបភាពជាហិរញ្ញប្បទានឥតសំណងសម្រាប់វិនិយោគ ឬ ការខ្ចី ដែលត្រូវកត់ត្រាក្នុងគម្រោងចំណូលទៅតាមលក្ខខណ្ឌដែលបានកំណត់ក្នុងកិច្ចព្រមព្រៀង ។ ធនធានសម្រាប់ទ្រទ្រង់ថវិកា និង សម្រាប់គម្រោង ត្រូវវាយតម្លៃទៅតាមលំហូរមូលនិធិ និង វឌ្ឍនភាពនៃការអនុវត្តគម្រោង ។ មូលនិធិបដិភាគក្រោមរូបភាពជាទំនិញត្រូវគ្រោងជាចំណូលនៃថវិការដ្ឋនូវចំនួនទឹកប្រាក់ដែលរំពឹងទុកតាមកម្មវិធីនៃការនាំចូលទំនិញទាំងនោះ

៥-ចំណូលមូលធនផ្សេងទៀត ។

**មាត្រា ៤៣.-**

គម្រោងចំណាយចរន្ត និង ចំណាយមូលធន ត្រូវរៀបចំឡើងដោយរដ្ឋបាលថ្នាក់ជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់គ្រប់សេវា និង សកម្មភាពទាំងមូល ។

**មាត្រា ៤៤.-**

ការគ្រោងនៃតម្រូវការថវិកាត្រូវផ្អែកលើគោលការណ៍ច្បាប់ និង គោលបំណងនៃគោលនយោបាយ កម្មវិធី សកម្មភាព និង លទ្ធផលរំពឹងទុក ដោយហ្មត់ចត់ និង ច្បាស់លាស់ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវបង្កើតនិយាម និង ឯកតារង្វាស់សម្រាប់រាល់សកម្មភាពការងារ ដែលមានលក្ខណៈផ្សេងៗគ្នា ព្រមទាំងសម្រាប់ទ្រព្យ និង សេវា ដោយសហការជាមួយក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែលពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។

ROYAUME DU CAMBODGE
MINISTÈRE DU PALAIS ROYAL

**មាត្រា ៤៥.-**

ចំណាយមូលធន ត្រូវផ្អែកលើកម្មវិធី ឬ គម្រោងដោយឡែកៗ ដែលមានការយល់ព្រមជាមុន និង ដែលត្រូវបានរៀបចំឡើងសំដៅសម្រេចឱ្យបាននូវគោលបំណង ដែលបានកំណត់ក្នុងរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល ។ កម្មវិធី ឬ គម្រោងទាំងអស់នោះគឺជាមូលដ្ឋានសម្រាប់វាយតម្លៃចំណាយមូលធនសរុបរបស់កម្មវិធី និង គម្រោង និង សម្រាប់កំណត់រយៈពេលនៃការសន្យា និង ការទូទាត់សម្រាប់ដំណាក់កាលនីមួយៗក្នុងឆ្នាំ ។

**មាត្រា ៤៦.-**

ដើម្បីគោរពតាមប្រតិទិននៃមាត្រា ៣៩ នៃច្បាប់នេះ ក្នុងការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានសិទ្ធិក្នុងការគ្រោងចំណូលចំណាយរបស់រដ្ឋបាលថ្នាក់ជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិដែលមិនបានលើកគម្រោងចំណូល ចំណាយរបស់ខ្លួនតាមកាលកំណត់ ដោយផ្អែកលើលទ្ធផលនៃឆ្នាំកំពុងអនុវត្ត ។

**មាត្រា ៤៧.-**

សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលត្រូវដាក់ជូនរដ្ឋសភា និង ព្រឹទ្ធសភា ត្រូវភ្ជាប់មកជាមួយនូវ :

១-របាយការណ៍វិភាគពីនិន្នាការ និង ការវិវត្តរួមនៃស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈបច្ចុប្បន្ន និង ការវិភាគលើចរិតលក្ខណៈនៃថវិកាថ្មី ព្រមទាំងបញ្ជាក់អំពីការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច សមតាហិរញ្ញវត្ថុ និងរូបិយវត្ថុជាសារវន្ត ពិសេសតុល្យភាពថវិកា ។

២-របាយការណ៍ទាំងឡាយ ដែលទាក់ទងទៅនឹងនិន្នាការ ចំណាយចរន្តដោយវិភាគ និង បង្ហាញពីស្ថានភាពឥណទានពាក់ព័ន្ធនឹងការអនុម័តឆ្នាំមុនទៅនឹងតម្រូវការ និង វិធានការថ្មី ដែលមានសារសំខាន់ចាំបាច់សម្រាប់ការគ្រប់គ្រងថ្មី ។

៣-កម្រងកម្មវិធី និង គម្រោងចំណាយមូលធន ដែលរំលេចនូវឥណទានវិនិយោគឥណទានភ្ជាប់សន្យា និង ឥណទានទូទាត់សម្រាប់កម្មវិធី និង គម្រោងក្នុងឆ្នាំ ការគ្រោងសរុបឥណទានដែលមានប្រភេទដូចគ្នាចាំបាច់សម្រាប់បន្តកម្មវិធី និង គម្រោងទាំងនេះ និង

ការវិភាគកម្មវិធី និង គម្រោងថ្មី ព្រមទាំងតម្រូវការឥណទានសម្រាប់កម្មវិធី និង គម្រោងថ្មី ទាំងនេះ ដោយកំណត់តាមប្រតិទិនប្រើប្រាស់ដែលបានគ្រោងទុក ។

៤-ឯកសារពាក់ព័ន្ធផ្សេងៗទៀត ដែលចាំបាច់សម្រាប់ជាព័ត៌មាន និង សម្រាប់ការត្រួតពិនិត្យរបស់រដ្ឋសភា និង ព្រឹទ្ធសភា ។

**មាត្រា ៤៨.-**

សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ចែកចេញជាពីរផ្នែក :

ផ្នែកទី ១ សេចក្តីព្រាងច្បាប់អនុញ្ញាតឱ្យប្រមូលគ្រប់ធនធានសាធារណៈ និង កំណត់ធនធានទាំងនោះ ជាទឹកប្រាក់សរុប ។ សេចក្តីព្រាងច្បាប់ត្រូវកំណត់ទិសដៅ និង មធ្យោបាយអនុវត្តចំពោះចំណាយមូលធន ។ សេចក្តីព្រាងច្បាប់បានកំណត់នូវឥណទានត្រូវផ្តល់ខ្ពស់បំផុត ដែលជាគុណប្រយោជន៍ដល់ថវិការដ្ឋ និង គណនីពិសេសរបស់រតនាគារជាតិ ។ សេចក្តីព្រាងច្បាប់រួមមានបទប្បញ្ញត្តិទាំងឡាយ ដែលទាក់ទងដល់ចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ ចំណូលមូលធន និង ទាក់ទងដល់គ្រប់បទប្បញ្ញត្តិហិរញ្ញវត្ថុផ្សេងៗទៀត ។

ផ្នែកទី ២ រួមមានតារាងបែងចែកជាក្រុម ប្រភេទ ជំពូក គណនី និង អនុគណនី ដែលទាក់ទងដល់ចំណូលនៃថវិការដ្ឋ ។ សេចក្តីព្រាងច្បាប់មានគម្រោងចំណាយចរន្តរបស់ថវិការដ្ឋ បែងចែកទៅតាមក្រសួង ស្ថាប័ន និង អង្គភាពសាធារណៈប្រហាក់ប្រហែល ហើយ បែងចែកទៅតាមប្រភេទចំណាយ ដែលត្រូវអនុម័ត ។ សេចក្តីព្រាងច្បាប់មានគម្រោងចំណាយមូលធន បែងចែកទៅតាមក្រសួង ស្ថាប័ន និង អង្គភាពសាធារណៈប្រហាក់ប្រហែល និង ជាជំពូកដែលចែកចេញជា ឥណទានភ្ជាប់សន្យា និង ឥណទានទូទាត់ ។ សេចក្តីព្រាងច្បាប់ត្រូវកំណត់បញ្ជីគណនីពិសេសរបស់រតនាគារជាតិ ដែលមានលក្ខណៈរដ្ឋបាល និង កំណត់គណនីពិសេសនីមួយៗនូវចំនួនទឹកប្រាក់ចំណូល និង ចំនួនទឹកប្រាក់ចំណាយ ។

**មាត្រា ៤៩.-**

ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវអនុម័តដោយរដ្ឋសភា និង ពិនិត្យដោយព្រឹទ្ធសភា និង ត្រូវ

ប្រកាសឱ្យប្រើដោយព្រះរាជក្រម ហើយត្រូវបោះផ្សាយឱ្យអនុវត្តជាច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៥០.-**

ប្រសិនបើសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ មិនត្រូវបានអនុម័តមុនថ្ងៃទី ០១ ខែមករានៃឆ្នាំការិយបរិច្ឆេទទេនោះ ថវិកាឆ្នាំមុនត្រូវបានបន្តដោយស្របច្បាប់ក្នុងលក្ខខណ្ឌដូចខាងក្រោម :

១-ចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និង ចំណូលគ្រប់ប្រភេទផ្សេងទៀតត្រូវបានអនុញ្ញាត និង បន្តឱ្យប្រមូលក្នុងលក្ខខណ្ឌ និង តាមបែបបទដែលបានកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុពីមុន និង ក្នុងក្របខ័ណ្ឌច្បាប់ ព្រមទាំងបទបញ្ញាដែលមានជាធរមាន

២-ចំណាយចរន្ត ក្រៅពីបន្ទុកបំណុលសាធារណៈ នៅតែបន្តអនុវត្តតាមក្របខ័ណ្ឌនៃថវិកាឆ្នាំមុន ដោយគិតតាមវិធីមួយភាគដប់ពីរជាបណ្តោះអាសន្នក្នុងខែនីមួយៗ រហូតដល់ថវិកាថ្មីត្រូវបានអនុម័ត

៣-ចំណាយមូលធននៃថវិកាក្រៅពីរំលស់បំណុលសាធារណៈ នៅតែបន្តអនុវត្តតាមក្របខ័ណ្ឌនៃថវិកាឆ្នាំមុន ក្នុងក្របខ័ណ្ឌឥណទានទូទាត់ដែលនៅទំនេរ ហើយអាចលើសពីនេះប្រសិនបើចាំបាច់ ដោយមិនឱ្យការទូទាត់នោះលើសពីកម្រិតឥណទានភ្ជាប់សន្យាដែលបានអនុម័តក្នុងថវិកាឆ្នាំមុន ។

៤-ចំណាយទាំងឡាយ ដែលជាកាតព្វកិច្ចទាក់ទងទៅនឹងសមាជិកភាពរបស់កម្ពុជាក្នុងស្ថាប័នអន្តរជាតិ និង អន្តររដ្ឋាភិបាល និង កាតព្វកិច្ចទាក់ទងទៅនឹងបន្ទុកបំណុលសាធារណៈរួមមានការរំលស់ប្រាក់ដើម ការបង់ការប្រាក់ កម្រៃសេវា និង/ ឬ ការបង់ពិន័យជាយថាហេតុ ត្រូវបានរ៉ាប់រងជាបន្តមិនឱ្យដាច់តាមកិច្ចព្រមព្រៀងជាធរមាន ។

/.

ROYAUME DU CAMBODGE · MINISTÈRE DU PALAIS ROYAL · ក្រសួងព្រះបរមរាជវាំង

## ផ្នែកទី ៣
## សិទ្ធិអំណាច និង ការទទួលខុសត្រូវ

**មាត្រា ៥១.-**

ច្បាប់ហិរញ្ញវត្ថុ ត្រូវអនុម័តក្នុងលក្ខខណ្ឌដូចគ្នានឹងច្បាប់ដទៃទៀតដែរ លើកលែងតែករណីពិសេសដូចខាងក្រោម :

-គម្រោងចំណូល ត្រូវអនុម័តសរុបជាកញ្ចប់ទាំងសម្រាប់ចំណូលចរន្តទាំងសម្រាប់ចំណូលមូលធន

-គម្រោងចំណាយ ត្រូវអនុម័តជាសរុបទាំងប្រភេទចំណាយចរន្ត ទាំងប្រភេទចំណាយមូលធនលើបញ្ជីក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែល

-ចំពោះគណនីពិសេសរបស់រតនាគារជាតិ ត្រូវអនុម័តសរុបជាកញ្ចប់លើបញ្ជីនៃគណនីទាំងអស់ដែលមាន

-បទប្បញ្ញត្តិទាំងអស់នៃច្បាប់ហិរញ្ញវត្ថុជាកម្មវត្ថុនៃការអនុម័តចុងក្រោយបង្អស់ ។

**មាត្រា ៥២.-**

គ្មានវិសោធនកម្មណាមួយ លើសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុអាចត្រូវបានអនុញ្ញាតឱ្យធ្វើនោះទេ ប្រសិនបើវិសោធនកម្មនោះធ្វើឱ្យប៉ះពាល់ដល់តុល្យភាពនៃគម្រោងថវិកាដែលបានស្នើឡើង ។ វិសោធនកម្មប្រភេទនេះ អាចធ្វើទៅបានតែក្នុងលក្ខខណ្ឌដូចខាងក្រោម :

- សំណើចំណាយថ្មី ត្រូវបានប៉ះប៉ូវដោយការលុបចេញ ឬ បន្ថយចំណាយណាមួយផ្សេងទៀត ដើម្បីរក្សាតុល្យភាពថវិកា

- សំណើចំណាយថ្មីត្រូវបានធ្វើឡើង ដោយមានភ្ជាប់ជាមួយនូវសំណើសន្សំសំចៃលើប្រភេទចំណាយណាមួយដែលបានស្នើឡើងរួចហើយ ដើម្បីរក្សាតុល្យភាពថវិកា

- សំណើចំណាយថ្មី ត្រូវបានធ្វើឡើងដោយមានភ្ជាប់ជាមួយនូវសំណើបង្កើតមុខចំណូលថ្មី ឬ បង្កើនចំណូល ដើម្បីរក្សាតុល្យភាពថវិកា

ROYAUME DU CAMBODGE * PALAIS ROYAL

វិសោធនកម្មដែលធ្វើឡើងផ្ទុយនឹងបទប្បញ្ញត្តិខាងលើនៃមាត្រានេះ នឹងត្រូវបានបដិសេធ ហើយទុកជាមោឃៈ ។

**មាត្រា ៥៣.–**

ការបែងចែកឥណទានជាជំពូក ត្រូវធ្វើឡើងដោយអនុក្រឹត្យ ។ អនុក្រឹត្យបែងចែកនេះ មិនអាចនាំឱ្យមានការប្រែប្រួលឥណទាន ដែលត្រូវបានកំណត់ដោយច្បាប់ ។

**មាត្រា ៥៤.–**

ការបែងចែកឥណទានលម្អិតនៅក្នុងជំពូក ជាគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ជំពូកទី ៤

## ការអនុវត្តថវិកា

### ផ្នែកទី ១

### ក្របខ័ណ្ឌនៃការអនុវត្តថវិកា

**មាត្រា ៥៥.–**

ការផ្ទេរឥណទានពីក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែលមួយទៅមួយទៀត ត្រូវកំណត់ដោយច្បាប់ហិរញ្ញវត្ថុ ។ ប៉ុន្តែការផ្ទេរឥណទានពីក្រសួងមួយពីស្ថាប័ន ឬ ពីអង្គភាពសាធារណៈប្រហាក់ប្រហែលមួយទៅមួយទៀត ដោយភាពចាំបាច់នៃការងារពង្រឹងរចនាសម្ព័ន្ធ ឬ រដ្ឋបាលរបស់រាជរដ្ឋាភិបាល អាចប្រព្រឹត្តទៅបានដោយអនុក្រឹត្យ ក្នុងករណីការផ្ទេរឥណទាននេះ មិនកែប្រែមុខចំណាយ និង ការបែងចែកឥណទានតាមជំពូកនីមួយៗទេ ។

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

មាត្រា ៥៦.-

ការបង្វែរឥណទានពីជំពូកមួយទៅជំពូកមួយ នៅផ្ទៃក្នុងថវិការបស់ក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែល ត្រូវធ្វើឡើងដោយអនុក្រឹត្យ ក្នុងករណីមិនកែប្រែឥណទានចំណាយមូលធនសម្រាប់វិនិយោគទៅជាឥណទានចំណាយចរន្តសម្រាប់ដំណើរការ ។

មាត្រា ៥៧.-

ការបង្វែរឥណទានពីគណនីមួយទៅគណនីមួយ ឬ ពីអនុគណនីមួយទៅអនុគណនីមួយ នៅក្នុងជំពូកតែមួយ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មាត្រា ៥៨.-

អនុក្រឹត្យ ដែលធ្វើឡើងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាចបែងចែកឥណទានថវិកា ដែលកត់ត្រានៅក្នុងចំណាយមិនបានគ្រោងទុកក្រោមរូបភាពនៃឥណទានបន្ថែមជាគុណប្រយោជន៍ដល់ជំពូកផ្សេងៗរបស់ក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែលនានា ។

មាត្រា ៥៩.-

ឥណទានដែលលែងមានមុខសញ្ញាប្រើប្រាស់ នៅក្នុងការិយបរិច្ឆេទនៃឆ្នាំថវិកា អាចត្រូវបានលុបចោលដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រោយពីបានទទួលព័ត៌មានពីរដ្ឋបាលថ្នាក់ជាតិ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ ។

មាត្រា ៦០.-

នៅពេលដែលការវិវត្តនៃចំណូល និង ចំណាយស្តែងចេញឱ្យឃើញនូវការបាត់តុល្យភាពថវិកា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាចចេញជាប្រកាស ដើម្បីបង្កកមួយចំណែក ឬ ទាំងស្រុងនៃប្រភេទឥណទានមួយចំនួនដែលបានអនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុ ។ ក្នុងករណីដែលការបាត់តុល្យភាពនេះមានលក្ខណៈធ្ងន់ធ្ងរ រាជរដ្ឋាភិបាលអាចធ្វើនីតិវិធីតាមអនុក្រឹត្យ

ROYAUME du CAMBODGE · LE MINISTRE du PALAIS ROYAL

តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយលុបចោលមួយចំណែក ឬទាំងស្រុងនៃប្រភេទឥណទានមួយចំនួនដែលបានអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

**មាត្រា ៦១.-**

ក្នុងករណីដែលមានគ្រោះធម្មជាតិ ឬ ភាពចាំបាច់ជាបន្ទាន់ដល់ផលប្រយោជន៍ជាតិ ដោយផ្អែកលើរបាយការណ៍របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រាជរដ្ឋាភិបាលអាចចេញអនុក្រឹត្យបន្ថែមឥណទានដើម្បីប្រើប្រាស់ ។ ឥណទាននេះ ត្រូវអនុម័តដោយច្បាប់កែតម្រូវនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលរាជរដ្ឋាភិបាលត្រូវសុំការយល់ព្រមពីរដ្ឋសភា និង ព្រឹទ្ធ-សភាភ្លាម នៅពេលដែលស្ថានការណ៍ពិសេសទាំងនេះត្រូវបានចប់សព្វគ្រប់ ។

ដោយបដិបញ្ញត្តិនៃកថាខណ្ឌខាងលើនៃច្បាប់នេះ បើច្បាប់កែតម្រូវនៃច្បាប់ហិរញ្ញវត្ថុនេះ ពុំអាចធ្វើទៅកើតក្នុងត្រីមាសទី ៤ នៃការិយបរិច្ឆេទនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ ឥណទានទាំងនេះជាកម្មវត្ថុនៃនិយ័តភាវូបនីយកម្មក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំបន្ទាប់ ។

**មាត្រា ៦២.-**

ការកែប្រែផ្សេងៗទៀតលើច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ អាចធ្វើទៅបាននៅក្នុងអំឡុងពេលនៃឆ្នាំថវិកាតាមរយៈច្បាប់កែតម្រូវនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលត្រូវដាក់ជូនរដ្ឋសភា និង ព្រឹទ្ធសភាអនុម័តដូចការអនុម័តច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំដែរ ។

## ផ្នែកទី ២
## ដំណើរការនៃការអនុវត្តថវិកា

**មាត្រា ៦៣.-**

ការអនុវត្តកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ និង គណនីពិសេសរបស់រតនាគារជាតិជាភារកិច្ចរបស់អាណាប័ក និង គណនេយ្យករសាធារណៈ ។ អាណាប័ក និង គណនេយ្យករសាធារណៈ មានមុខងារវិសមិតភាពនឹងគ្នា ។

រដ្ឋមន្ត្រី ប្រធានស្ថាប័ន និង ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែលជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួន ទាំងនៅរដ្ឋបាលថ្នាក់ជាតិ និង ទាំងនៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមខ្សែបណ្តោយដែលស្ថិតក្រោមឱវាទ ។ អាណាប័កដើមខ្សែជាអ្នកបញ្ជាចំណូល និង បញ្ជាចំណាយថវិកាតាមផ្នែករៀងៗខ្លួន ។

រដ្ឋមន្ត្រី ប្រធានស្ថាប័ន និង ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល ដែលជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួន អាចប្រគល់សិទ្ធិជូនអភិបាលរដ្ឋបាលថ្នាក់ក្រោមជាតិជាអាណាប័កផ្ទេរសិទ្ធិ សម្រាប់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនៃថវិកាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ រដ្ឋមន្ត្រី ប្រធានស្ថាប័ន និង ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល ដែលជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួន អាចប្រគល់សិទ្ធិជូនប្រធានអង្គភាពក្រោមឱវាទ ប្រធានមន្ទីរជំនាញខេត្ត និង រាជធានី ជាអាណាប័កផ្ទេរសិទ្ធិសម្រាប់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនៃថវិកា បន្ទាប់ពីមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ក្នុងករណីអាណាប័កដើមខ្សែ ឬ អាណាប័កតាមការប្រទានសិទ្ធិ អវត្តមាន ឬ មានធុរៈ អាចជ្រើសតាំងប្រភេទមន្ត្រីរាជការ ដើម្បីផ្ទេរសិទ្ធិ ឬ ជំនួសខ្លួន ដោយផ្អែកលើបទបញ្ជាគណនេយ្យសាធារណៈ ។ ការផ្ទេរសិទ្ធិ ឬ ការចុះហត្ថលេខា ត្រូវធ្វើឡើងដោយប្រកាសបន្ទាប់ពីមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ៦៤.–**

ចំណាយលើថវិការដ្ឋ និង លើគណនីពិសេសរបស់រតនាគារជាតិ ជាកម្មវត្ថុនៃការឆ្លងទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលបានទទួលការតែងតាំងពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ គោលបំណង និង ហេតុផលជាក់ស្តែងនៃការត្រួតពិនិត្យនេះ ព្រមទាំងវិធីសាស្ត្រនៃកិច្ចប្រតិបត្តិការ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

CAMBODGE PALAIS ROYAL

**មាត្រា ៦៥.-**

ចំណាយថវិការដ្ឋរួមទាំងថវិកាថ្នាក់ជាតិ និង ថវិកាថ្នាក់ក្រោមជាតិ និង ថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងគណនីពិសេសរបស់រតនាគារជាតិក្នុងការទិញ ការជួសជុល ការសាងសង់ និង ការផ្តល់សេវា ត្រូវអនុវត្តតាមវិធីសាស្ត្រ និង នីតិវិធីលទ្ធកម្មសាធារណៈ ដែលត្រូវបានកំណត់ដោយច្បាប់ និង បទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ។

## ផ្នែកទី ៣
## សិទ្ធិអំណាច និង ការទទួលខុសត្រូវ

**មាត្រា ៦៦.-**

រដ្ឋមន្ត្រី ប្រធានស្ថាប័ន និង ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែលព្រមទាំងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ មានកាតព្វកិច្ចទទួលខុសត្រូវចំពោះការអនុវត្តថវិការបស់ខ្លួន ។ ចំពោះការប្រមូលចំណូល និង ការអនុវត្តចំណាយត្រូវគោរពទៅតាមព្រំដែននៃសិទ្ធិអំណាចរបស់ខ្លួនដែលច្បាប់បានកំណត់ ។

**មាត្រា ៦៧.-**

ស្ថិតក្រោមកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុ និង ក្រោមអំណាចរបស់នាយករដ្ឋមន្ត្រីមានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមួយគត់ ដែលមានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេ ការបោះផ្សាយមូលបត្ររដ្ឋ ការទទួលហិរញ្ញប្បទានឥតសំណង ការវិនិយោគលើអចលកម្មហិរញ្ញវត្ថុ ការធានា និង ការសន្សាផ្នែកហិរញ្ញវត្ថុនានា និង មានសិទ្ធិ ក្នុងការឱ្យប្រាក់គេខ្ចីទាំងក្នុង និង ក្រៅប្រទេស ។ គ្មានរដ្ឋមន្ត្រីដទៃណាទៀត ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល ប្រធានសហគ្រាសសាធារណៈ អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ឬ មន្ត្រីសាធារណៈណាមួយ មានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេ ឬ ឱ្យប្រាក់គេខ្ចី ឬ ចេញជាលិខិតធានា ឬ ក៏ធ្វើទង្វើណាផ្សេងៗទៀតដោយផ្ទាល់ ឬ ដោយប្រយោល ដែលអាចនាំឱ្យកើតមាននូវបំណុល ឬ បន្ទុកហិរញ្ញវត្ថុផ្សេងទៀត ដោយផ្ទាល់ ឬ ដោយប្រយោលដល់ព្រះរាជាណាចក្រកម្ពុជា បាន

ROYAUME DU CAMBODGE · LE MINISTÈRE ROYAL

**មាត្រា ៦៨.-**

ស្ថិតក្រោមកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុ និង ក្រោមអំណាចរបស់នាយករដ្ឋមន្ត្រី មានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុតែមួយគត់ ដែលមានសិទ្ធិរៀបចំកម្មវិធីដោះស្រាយបំណុលដែលរដ្ឋជំពាក់គេ ឬ បំណុលដែលគេជំពាក់រដ្ឋ ។ ការរៀបចំកម្មវិធីដោះស្រាយបំណុល ត្រូវកំណត់ដោយច្បាប់ហិរញ្ញវត្ថុ ។

**មាត្រា ៦៩.-**

លក្ខខណ្ឌផ្នែកហិរញ្ញវត្ថុ និង ទំហំទឹកប្រាក់នៃការខ្ចីប្រាក់ពីគេនៃការឱ្យប្រាក់គេខ្ចីនៃការបោះផ្សាយមូលបត្ររដ្ឋ នៃការធានា និង នៃការសន្យាផ្នែកហិរញ្ញវត្ថុនានា ត្រូវកំណត់ដោយច្បាប់ហិរញ្ញវត្ថុ ។

**មាត្រា ៧០.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចគ្រប់គ្រងលទ្ធកម្មសាធារណៈ និងណែនាំក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ។ ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល ស្ថាប័នថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈ និង សហគ្រាសសាធារណៈ ត្រូវគោរពតាមច្បាប់ អនុក្រឹត្យ ប្រកាស និង សេចក្តីណែនាំទាំងឡាយស្តីពីលទ្ធកម្មសាធារណៈ ។

## ជំពូកទី ៥

## គណនេយ្យ និង ការត្រួតពិនិត្យលទ្ធផល

### ផ្នែកទី ១

### ក្របខ័ណ្ឌគណនេយ្យ និង ការទូទាត់ថវិកា

**មាត្រា ៧១.-**

គោរពតាមគោលការណ៍គណនេយ្យភាព រដ្ឋមន្ត្រី ប្រធានស្ថាប័ន ប្រធានអង្គភាពសា-ធារណៈប្រហាក់ប្រហែល និង អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិមានភារកិច្ចរៀបចំ និង

ផ្តល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនូវរបាយការណ៍ស្តីពីការអនុវត្តថវិកា របាយការណ៍ស្តីពីការអនុវត្តគម្រោងដែលពាក់ព័ន្ធនឹងការខ្ចីប្រាក់គេ ការបោះផ្សាយមូលបត្ររដ្ឋ ការធានា និង ការសន្យានានាផ្នែកហិរញ្ញវត្ថុ ការទទួលហិរញ្ញប្បទានឥតសំណង និង ដែលពាក់ព័ន្ធនឹងចំណូលមានប្រភពមកពីការវិនិយោគលើអចលកម្មហិរញ្ញវត្ថុ និង ព័ត៌មានចាំបាច់ផ្សេងៗទៀតតាមតម្រូវការរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកាតព្វកិច្ចកំណត់កាលបរិច្ឆេទនៃការផ្តល់និងគំរូនៃរបាយការណ៍ ដូចមានចែងក្នុងវាក្យខណ្ឌខាងលើនៃមាត្រានេះ ដើម្បីជូនរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានគ្រប់អង្គភាពសាធារណៈប្រហាក់ប្រហែល និង អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្ត ។

**មាត្រា ៧២.-**

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានគ្រប់អង្គភាពសាធារណៈប្រហាក់ប្រហែល ប្រធានសហគ្រាសសាធារណៈ និង អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ មានកាតព្វកិច្ចទទួលខុសត្រូវក្នុងការរៀបចំក្របខ័ណ្ឌ និង គ្រប់គ្រងកិច្ចប្រតិបត្តិការការត្រួតពិនិត្យផ្ទៃក្នុងរបស់ខ្លួន ដើម្បីធានាភាពត្រឹមត្រូវ និង ស្របតាមបទដ្ឋាន បទប្បញ្ញត្តិ និង សេចក្តីណែនាំរបស់រាជរដ្ឋាភិបាល ។

ដោយឡែក រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានកាតព្វកិច្ចទទួលខុសត្រូវក្នុងការណែនាំអំពីការរៀបចំក្របខ័ណ្ឌ កិច្ចប្រតិបត្តិការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល សហគ្រាសសាធារណៈ និង រដ្ឋបាលថ្នាក់ក្រោមជាតិ និងមានភារកិច្ចធ្វើអធិការកិច្ចហិរញ្ញវត្ថុ នៅតាមក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ៧៣.-**

កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និង គណនេយ្យសាធារណៈទាំងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវប្រមូលផ្តុំនៅរតនាគារជាតិ និង អនុវត្តដោយគណនេយ្យករសាធារណៈ ។

ROYAUME DU CAMBODGE

**មាត្រា ៧៤.-**

ប្រព័ន្ធគណនេយ្យសាធារណៈ ត្រូវមានសង្គតិភាពទៅនឹងនិយាមគណនេយ្យអន្តរជាតិ ដែលមានការទទួលស្គាល់ជាទូទៅ ហើយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវចេញប្រកាសកំណត់ប្រព័ន្ធគណនេយ្យនេះ ។

**មាត្រា ៧៥.-**

បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ត្រូវកំណត់គ្រប់លក្ខខណ្ឌ ដែលធ្វើឱ្យប្រតិបត្តិការគណនេយ្យ និង ហិរញ្ញវត្ថុ អាចកត់ត្រាវិភាគ និង គ្រប់គ្រងការអនុវត្តច្បាប់ហិរញ្ញវត្ថុ ប្រកបដោយគណនេយ្យភាព ភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាព ។

**មាត្រា ៧៦.-**

ការទូទាត់ថវិកា គឺជាកម្មវត្ថុនៃច្បាប់ ។

**មាត្រា ៧៧.-**

សេចក្តីព្រាងច្បាប់ទូទាត់ថវិកា ពិនិត្យកត់ត្រានូវចំនួនទឹកប្រាក់ជាស្ថាពរនៃចំណូលដែលបានបង់ចូលក្នុងគណនីទោលរបស់រតនាគារជាតិ និង អាណាប័ណ្ណចំណាយដែលបានប្រព្រឹត្តនៅក្នុងការិយបរិច្ឆេទនៃឆ្នាំថវិកា ។ សេចក្តីព្រាងច្បាប់នេះទុកជាមោឃៈនូវឥណទានដែលមិនបានប្រើប្រាស់ ហើយលើកឡើងឱ្យឃើញនូវលទ្ធផលហិរញ្ញវត្ថុពិតនៃឆ្នាំ ដោយធ្វើការកត់ត្រាទៅក្នុង "គណនីលទ្ធផល" របស់រតនាគារជាតិ ។

**មាត្រា ៧៨.-**

សេចក្តីព្រាងច្បាប់ទូទាត់ថវិកា ត្រូវរៀបចំដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទៅតាមមាតិកាថវិកានីមួយៗ ដោយផ្អែកលើទិន្នន័យចំណូល ចំណាយ ដែលរាយការណ៍ដោយគណនេយ្យករសាធារណៈ ក្រោយពីបានធ្វើការផ្ទៀងផ្ទាត់ត្រឹមត្រូវជាមួយអាណាប័កពាក់ព័ន្ធ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៧៩.–**

ក្របខ័ណ្ឌ និង កិច្ចដំណើរការនៃសវនកម្មផ្ទៃក្រៅត្រូវអនុវត្តតាមច្បាប់ស្ដីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៨០.–**

ប្រតិបត្តិការ ដែលបង្ហាញនៅក្នុងសេចក្ដីព្រាងច្បាប់ទូទាត់ថវិកា ត្រូវឆ្លុះបញ្ចាំងនូវវិធានគណនេយ្យសាធារណៈតាមលំនាំដូចខាងក្រោម :

១-ចំពោះចំណូល : ការគ្រោងទុកដើមគ្រា ព្រមទាំងការកែប្រែ និង ចំណូលជាក់ស្ដែង ដែលបែងចែកតាមក្រុម ប្រភេទ ជំពូក គណនី និង អនុគណនី ។

២-ចំពោះចំណាយ : ការគ្រោងទុកដើមគ្រា ការអនុញ្ញាតថ្មី និង ចំណាយជាក់ស្ដែងនៅតាមក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែល និង រដ្ឋបាលថ្នាក់ក្រោមជាតិទៅតាមមាតិកាថវិកា ។

៣-ការប្រៀបធៀបទឹកប្រាក់សរុបនៃការគ្រោងទុកនៃចំណូល និង ចំណាយ និង ការកែប្រែដែលបានធ្វើ ប្រសិនបើមានជាមួយនឹងលទ្ធផលចុងក្រោយនៃថវិការបស់រដ្ឋបាលសាធារណៈនីមួយៗ ។

ប្រតិបត្តិការ ដែលបង្ហាញនៅក្នុងសេចក្ដីព្រាងច្បាប់ទូទាត់ថវិកា ទាំងថវិការដ្ឋ និង ទាំងគណនីពិសេសរបស់ធនាគារជាតិ ត្រូវបង្ហាញជាលម្អិតនូវឥណទានដែលបានអនុម័តដើមឆ្នាំ និងឥណទានកែតម្រូវទៅតាមមាតិកាថវិកា ។

**មាត្រា ៨១.–**

សេចក្ដីព្រាងច្បាប់ទូទាត់ថវិកា ដែលត្រូវដាក់ជូនរដ្ឋសភាសុំការអនុម័ត និង ព្រឹទ្ធសភាសុំការពិនិត្យ ត្រូវភ្ជាប់ជាមួយនូវ :

១-របាយការណ៍វិភាគស្ដីពីលទ្ធផលនៃការប្រមូលចំណូល និង ស្ថានភាពនៃការអនុវត្តចំណាយថវិកា ។

២-របាយការណ៍ស្ដីពីស្ថានភាពទូទៅនៃសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនៅក្នុងឆ្នាំអនុវត្តនិង

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

ស្តីពីស្ថានភាពនៃការសម្រេចបាននូវតុល្យភាពម៉ាក្រូសេដ្ឋកិច្ច ។

៣-តារាងតុល្យការរបស់រាជរដ្ឋាភិបាល ។

ក្រោយពី បានប្រកាសឱ្យប្រើច្បាប់ទូទាត់ថវិកា ត្រូវបោះផ្សាយដូចគ្នានឹងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំដែរ ។

## ផ្នែកទី ២
## សិទ្ធិអំណាច និង ការទទួលខុសត្រូវ

### មាត្រា ៨២.-

គណនេយ្យករសាធារណៈ ទទួលបន្ទុកប្រមូលចំណូល ទូទាត់ចំណាយរក្សាទុកដាក់មូលនិធិមូលបត្រ ផលិតផល និង សម្ភារៈដែលជាកម្មសិទ្ធិរបស់ស្ថាប័នសាធារណៈ ។ មានតែគណនេយ្យករសាធារណៈមួយគត់ ដែលមានសិទ្ធិអំណាចក្នុងការអនុវត្តប្រតិបត្តិការទាំងឡាយ និង ដោះស្រាយបញ្ហាមូលនិធិពាក់ព័ន្ធដទៃទៀតជាមួយចំណូល និង ចំណាយ ។

ក្នុងសមត្ថកិច្ចនេះ គណនេយ្យករសាធារណៈ មានការទទួលខុសត្រូវជាលក្ខណៈបុគ្គល និង ជាប្រាក់កាស ។

### មាត្រា ៨៣.-

គណនេយ្យករសាធារណៈ ត្រូវបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញ-វត្ថុ ។ គណនេយ្យករសាធារណៈមានអំណាចពិសេសរបស់ខ្លួន ។ មុនចូលកាន់តំណែង គណ-នេយ្យករសាធារណៈ ត្រូវតែធ្វើសច្ចាប្រណិធានជាផ្លូវការតាមបែបបទត្រឹមត្រូវនៅចំពោះមុខអាជ្ញាធរមានសមត្ថកិច្ច ។ អាណាប័កដើមខ្សែ និង អាណាប័កផ្ទេរសិទ្ធិព្រមទាំងគណនេយ្យករសាធារណៈដទៃទៀត ត្រូវទទួលស្គាល់គណនេយ្យករសាធារណៈ ដែលបានទទួលការតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ៨៤.–**

រាល់ការអនុវត្តចំណូល និង ចំណាយនៃថវិការដ្ឋ ត្រូវធ្វើឡើងទៅតាមបទប្បញ្ញត្តិ និង សេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ រាល់ការកត់ត្រា ចំណូល និង ចំណាយរបស់រដ្ឋបាលថ្នាក់ជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវគោរពទៅតាមប្លង់គណនេយ្យ និង មាតិកាថវិកា ហើយរាល់របាយការណ៍គណនេយ្យ និង ហិរញ្ញវត្ថុ ត្រូវមានតម្លាភាព និង ផ្សព្វផ្សាយជាសាធារណៈ ។

រាល់ប្រតិបត្តិការហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានសិទ្ធិចាត់តាំងមន្ត្រីក្រោមឱវាទចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែល សហគ្រាសសាធារណៈ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានអនុវត្តប្រតិបត្តិការថវិការដ្ឋ ដើម្បីធានាការប្រមូលបាននូវព័ត៌មាន និង ទិន្នន័យច្បាស់លាស់សម្រាប់ការរៀបចំទូទាត់ថវិកាប្រចាំឆ្នាំ ។

## ជំពូកទី ៦
## ទោសប្បញ្ញត្តិ

**មាត្រា ៨៥.–**

មន្ត្រីសាធារណៈគ្រប់ប្រភេទ និង គ្រប់ឋានៈ ដែលបានរកឃើញថាមិនបានគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ក្នុងការអនុវត្តមុខងារ និង ភារកិច្ចរបស់ខ្លួន ដែលរដ្ឋបានប្រគល់ជូន ត្រូវទទួលទណ្ឌកម្មខាងវិន័យទៅតាមច្បាប់ និង លិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌ និង ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផ្សេងទៀត ។ ក្នុងករណីកំហុសរបស់មន្ត្រីសាធារណៈនោះ បានធ្វើឱ្យមានការបាត់បង់ប្រាក់កាស ឬ ខូចខាតទ្រព្យសម្បត្តិសាធារណៈ នោះតម្លៃនៃការបាត់បង់ ឬ ការខូចខាត រួមទាំងការប្រាក់លើតម្លៃបាត់បង់ ឬ ខូចខាតនេះ នឹងក្លាយជាបំណុលចំពោះមន្ត្រីសាធារណៈនោះដែលត្រូវសង និង បង់ចូលថវិការដ្ឋវិញ ។

**មាត្រា ៨៦.-**

មន្ត្រីសាធារណៈ ដែលបញ្ជាក់នៅក្នុងមាត្រា ៨៥ នៃច្បាប់នេះ រួមបញ្ចូលទាំងមន្ត្រីសាធារណៈដែលកំពុងបម្រើការងារ និង មន្ត្រីសាធារណៈដែលធ្លាប់បានបម្រើការងារ ។

## ជំពូកទី ៧
## អន្តរប្បញ្ញត្តិ

**មាត្រា ៨៧.-**

បទប្បញ្ញត្តិនៃច្បាប់ពាក់ព័ន្ធផ្សេងទៀត ដែលផ្អែកលើមូលដ្ឋានច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ព្រមទាំង អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរណែនាំរបស់រាជរដ្ឋាភិបាល និង ប្រកាសសារាចរណែនាំផ្សេងៗរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលជាបទដ្ឋានគតិយុត្តគាំទ្រសម្រាប់ការអនុវត្តច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុខាងលើមានសុពលភាព អនុវត្តរហូតដល់មានបទប្បញ្ញត្តិនៃច្បាប់ អនុក្រឹត្យ.សេចក្តីសម្រេច បទបញ្ជា សារាចរណែនាំរបស់រាជរដ្ឋាភិបាល និង ប្រកាសសារាចរណែនាំផ្សេងៗរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមកជំនួសថ្មី ស្របតាមស្មារតីនៃច្បាប់នេះ ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ៨៨.-**

ច្បាប់នេះត្រូវមានអាទិភាព ប្រសិនបើមានបទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀតមិនស្របគ្នានឹងបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ។

**មាត្រា ៨៩.-**

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនេះ ត្រូវជំនួសច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ និងបទប្បញ្ញត្តិទាំងឡាយដែលជាវិសោធនកម្មនៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ។

**មាត្រា ៩០.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៩១.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៣ ខែឧសភាឆ្នាំ ២០០៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣៧.០៥០៥.៥៣៣ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
**ហត្ថលេខា**
**គាត ឈន់**

៤៩៤ ច.ល
**ដើម្បីចម្លងចែក**
ភ្នំពេញថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ២០០៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុន ចិនកេន**